**ឧត្តមស្នងការសិទ្ធិមនុស្ស មានប្រសាសន៍ប្រាប់ក្រុមប្រឹក្សាសិទ្ធិមនុស្សថា ជំងឺកូវីដ១៩ (COVID-19) គឺជា "ការសាកល្បងដ៏ធំសម្បើមនៃភាពជាអ្នកដឹកនាំ" ដែលទាមទារឲ្យមានសកម្មភាពសម្របសម្រួលគ្នា**

**ជំងឺរាតត្បាតកូវីដ១៩ (COVID-19) - ការរាយការណ៍ក្រៅផ្លូវការទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស**

**សេចក្តីថ្លែងការណ៍របស់លោកស្រី មីស្សែល បាស្សេឡេត ឧត្តមស្នងការ អ.ស ប ទទួលបន្ទុកសិទ្ធិមនុស្ស**

ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០

**លោកជំទាវប្រធាន**

**ឯកឧត្តម លោកជំទាវ**

**សហការី និងមិត្តភក្តិ**

ជាការពិតណាស់ នេះជាកិច្ចប្រជុំដ៏សំខាន់មួយ នៅខណៈដែលគ្មាននរណាម្នាក់នៃយើងទាំងអស់គ្នា អាចបំភ្លេចបានឡើយ។ ជំងឺរាតត្បាតកូវីដ១៩ (COVID-19) កំពុងធ្វើឲ្យមានការឈឺចាប់ និងបង្កការខូចខាតនៅគ្រប់តំបន់។ ជំងឺនេះបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់សិទ្ធិមនុស្ស។ ដូចដែលអគ្គលេខាធិការ អ.ស.ប លោក អង់តូនីញ្ញូ ហ្គុយតេរេស បានក្រើនរំលឹកថា **វាគំរាមកំហែងមិនត្រឹមតែដល់ការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង "បានបង្កើន អស្ថិរភាព បានបង្កើនភាពវឹកវរ និងបង្កើនជម្លោះ" ទៀតផង។**

យើងមិនដឹងថា តើវីរុសនេះ អាចវិវឌ្ឍយ៉ាងដូចម្តេច ឬថាតើអ្នកដែលរងផលប៉ះពាល់ នឹងមានភាពស៊ាំជារៀងរហូត ឬយ៉ាងណាទេ។ យើងមិនមានទិន្នន័យពេញលេញ អំពីអ្នកដែលបានឆ្លងមេរោគ និងវិវឌ្ឍរោគសញ្ញាធ្ងន់ធ្ងរបំផុត - ឬថា តើមានទំនាក់ទំនងជាមួយកត្តារួមផ្សំ ដូចជាការបំពុលជាដើម។ យើងដឹងថា វិធានការចាំបាច់ត្រូវតែមាន ដើម្បីពង្រឹងប្រព័ន្ធសុខាភិបាល និងសង្គម ដើម្បីធានាបាននូវការគាំទ្រដ៏រឹងមាំបំផុតដែលអាចធ្វើទៅបាន ចំពោះអ្នកដែលទទួលរងផលប៉ះពាល់ពីជំងឺរាតត្បាតនេះ។ យើងដឹងថា យើងមិនអាចទុកនរណាម្នាក់ចោលនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះបានឡើយ។

ហើយយើងដឹងថា ការបិទប្រទេស មិនអាចបន្តមានជារៀងរហូតបាននោះទេ។ យុទ្ធសាស្ត្រចាកចេញ ត្រូវតែបានបង្កើតឡើងយ៉ាងប្រុងប្រយ័ត្ន ដើម្បីធានាថា សង្គម និងប្រជាជនរបស់យើងវិលត្រឡប់មករកស្ថានភាពដូចដើមវិញ។

ថ្ងៃនេះ យើងបានមកចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការរបស់ក្រុមប្រឹក្សា បើទោះបីជារូបកាយយើងអាចនៅឆ្ងាយពីគ្នាក្តី។ ខ្ញុំសង្ឃឹមថា ទង្វើនេះ រួមចំណែកដល់**ការបង្កើនកិច្ចសហការជាសកលថែមទៀត ផ្អែកលើអភិក្រមសិទ្ធិមនុស្សចំពោះវិបត្តិនេះ។**

រដ្ឋទាំងអស់ កំពុងជួបបញ្ហាប្រឈមយ៉ាងខ្លាំង។ រដ្ឋជាច្រើន បាននិងកំពុងបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការការពារសិទ្ធិមនុស្ស តាមរយៈជំងឺរាតត្បាតនេះ។ រដ្ឋផ្សេងទៀត គួរត្រូវបានជម្រុញលើកទឹកចិត្តឲ្យធ្វើដូចនេះ ដើម្បីធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ដោះស្រាយបញ្ហាជំងឺកូវីដឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត សម្រាប់មនុស្សគ្រប់រូប - ទាំងនៅក្នុងប្រទេសរបស់ខ្លួន ក៏ដូចជាទាំងនៅទូទាំងពិភពលោក។

នេះជារឿងធម្មតា និងជាការចាំបាច់ សម្រាប់កិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិ ក្នុងការចាត់ជាអាទិភាពដ៏រឹងមាំនៅចំពោះវិបត្តិណាមួយ។ ប៉ុន្តែ នេះជាបញ្ហាជំងឺរាតត្បាតជាសាកល ហើយមានតែសាមគ្គីភាពជាសាកលទេ ដែលនឹងធានាថា យើងអាចប្រយុទ្ធប្រឆាំងនឹងជំងឺនេះបានប្រកបដោយប្រសិទ្ធភាព។ វិបត្តិនេះ បញ្ជាក់ច្បាស់អំពីវិសាលភាពកម្រិតណា ដែលយើងត្រូវការសកម្មភាពអន្តរជាតិជាសមូហភាព ហើយបង្ហាញពីគុណតម្លៃរបស់អង្គការពហុភាគីរបស់យើង។ អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើង ដើម្បីការពារ កាត់បន្ថយ និងដោះស្រាយកាន់តែមានប្រសិទ្ធភាពថែមទៀតនូវវិបត្តិអន្តរជាតិ។ ខ្ញុំសូមស្នើឲ្យយើងទាំងអស់គ្នា ធ្វើការរួបរួមគ្នាដើម្បីលើកកម្ពស់វិធីសាស្ត្រដ៏រឹងមាំ សហប្រតិបត្តិការពហុភាគីនិងមានលក្ខណៈជាសាកល។

**ជាបឋម ខ្ញុំសូមលើកយកបញ្ហាបន្ទាន់មួយចំនួន ទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច និងសង្គម**

ជំងឺរាតត្បាត កំពុងតែបង្ហាញពីផលប៉ះពាល់អវិជ្ជមាននៃ**វិសមភាព** នៅក្នុងសង្គមទាំងអស់។

នៅបណ្តាប្រទេសអភិវឌ្ឍន៍ មានកំហុសឆ្គងមួយចំនួន ក្នុងការទទួលបានសេវាគាំពារសុខភាព នៅក្នុងវិស័យសិទ្ធិការងារ និងការការពារសង្គម ក្នុងលំហការរស់នៅ និងក្នុងផ្នែកសេចក្តីថ្លៃថ្នូរ ដែលអាចមើលឃើញភ្លាមៗ។

ចំណែកឯនៅប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រជាជនភាគច្រើនពឹងផ្អែកលើប្រាក់ចំណូលប្រចាំថ្ងៃដើម្បីរស់ ផលប៉ះពាល់ អាចនឹងមានច្រើនជាងនេះ។ ប្រជាជនរាប់លាននាក់ដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាគាំពារសុខភាពហើយដែល ដោយភាពចាំបាច់ រស់នៅក្នុងស្ថានភាពចង្អៀត មិនមានអនាម័យល្អ ហើយគ្មានបណ្តាញសុវត្ថិភាព គ្មានទឹកស្អាត និងទទួលរងផលប៉ះពាល់ច្រើនជាងគេបំផុត។ ពួកគេទំនងជាមិនអាចការពារខ្លួនពីវីរុសបានទេ ហើយក៏ទំនងជាមិនអាចទប់ទល់នឹងការធ្លាក់ចុះនៃប្រាក់ចំណូលយ៉ាងខ្លាំងបានដែរ។

ដោយមិនបានត្រួតពិនិត្យ ជំងឺរាតត្បាតទំនងជានឹងបង្កើតវិសមភាពកាន់តែទូលំទូលាយថែមទៀត នៅចំពេលដែលមានការឈឺចាប់មិនអាចគណនាបាននេះ។

សកលភាពនៃការគំរាមកំហែងពីវីរុសនេះ ផ្តល់នូវអំណះអំណាងដ៏គួរឲ្យទាក់ទាញបំផុត ដែលមិនធ្លាប់មាន សម្រាប់ការទទួលបានកិច្ចគាំពារសុខភាពជាសាកល និងមានតំលៃសមរម្យ។ **សកម្មភាពលើកកំពស់កិច្ចគាំពារសុខភាពសាធារណៈ** នៅប្រទេសនីមួយៗ គឺមានភាពបន្ទាន់បំផុត។ អង្គការសុខភាពពិភពលោក កំពុងតែដឹកនាំកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាថា ប្រទេសទាំងអស់ ត្រូវបានបំពាក់គ្រឿងឧបករណ៍ដើម្បីតាមដាន ដាក់ឲ្យនៅដាច់ដោយឡែក និងព្យាបាលអ្នកឆ្លងជំងឺកូវីដ១៩ (COVID-19)។ កិច្ចខិតខំប្រឹងប្រែងនេះ គួរតែត្រូវបានផ្តល់ឲ្យបានពេញលេញ។ ការនេះ ចាំបាច់ត្រូវតែមានការខិតខំប្រឹងប្រែងក្នុងតំបន់នានា និងនៅលើពិភពលោក ដើម្បីជៀសវាងការដួលរលំនៃប្រព័ន្ធវេជ្ជសាស្ត្ររបស់ប្រទេសណាមួយ ដែលជាបញ្ហាត្រូវតែយកចិត្តទុកដាក់ជាបន្ទាន់សម្រាប់មនុស្សគ្រប់រូប។

វិធានការទូលំទូលាយខាងសេដ្ឋកិច្ច និងសង្គម ត្រូវចាត់ផងដែរ នៅក្នុងប្រទេសនីមួយៗ **ដើម្បីកាត់បន្ថយសន្ទុះនៃការរីករាលដាលនេះ និងកាត់បន្ថយការរីកលូតលាស់បន្ថែមទៀតនៃវិសមភាព។** ផលប៉ះពាល់ទាំងស្រុងនៃជំងឺរាតត្បាតទៅលើសេដ្ឋកិច្ចសាកល និងសេដ្ឋកិច្ចជាតិ នៅមិនទាន់ដឹងនៅឡើយទេ។ រដ្ឋជាច្រើននៅគ្រប់តំបន់ ជាពិសេសនៅអឺរ៉ុប បានចាត់វិធានការដែលមិនធ្លាប់មានពីមុនមក ដើម្បីការពារសិទ្ធិកម្មករ និងកាត់បន្ថយចំនួនអ្នកដែលអត់ការងារធ្វើ។ រដ្ឋទាំងអស់ដែលមានធនធានគ្រប់គ្រាន់ គួរត្រូវបានជម្រុញលើកទឹកចិត្តឲ្យធ្វើដូចគ្នាផងដែរ។

ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន មានសមត្ថភាពតិចតួចក្នុងការស្រូបយក និងកាត់បន្ថយផលប៉ះពាល់នៃជំងឺរាតត្បាតទៅលើសេដ្ឋកិច្ច និងសង្គម។ ពួកគេ អាចងាយរងគ្រោះបំផុតផងដែរ ពីវិបត្តិសេដ្ឋកិច្ចពិភពលោក តាមរយៈការកំណត់តម្លៃទំនិញ និងការធ្លាក់ចុះនៃការវិនិយោគបរទេស និងការផ្ទេរប្រាក់ ក្នុងចំណោមកត្តាផ្សេងទៀត។ លោកអគ្គលេខាធិការ បានអំពាវនាវឲ្យមានវិធានការមួយចំនួន រួមទាំង - ប៉ុន្តែ

មិនមានកំណត់ - ការកាត់បន្ថយបំណុល ពង្រីកលទ្ធភាពទទួលបានមូលនិធិតាមរយៈ មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងការចូលរួមវិភាគទានដល់មូលនិធិមនុស្សធម៌ពិភពលោក។

យើងក៏ប្រហែលជាត្រូវស្វែងរកយន្តការហិរញ្ញវត្ថុថ្មីៗ ដើម្បីផ្តល់មូលនិធិដល់សាមគ្គីភាពសាកល។ កាលពីសប្តាហ៍មុន ធនាគារអភិវឌ្ឍន៍អាហ្វ្រិក បានបង្កើនចំណាងសង្គមដ៏ធំបំផុតរបស់ពិភពលោក៖ មូលនិធិ ៣ ពាន់លានដុល្លារអាមេរិក ដើម្បីជួយដល់រដ្ឋាភិបាលអាហ្វ្រិក ក្នុងការពង្រីកលទ្ធភាពទទួលបានសុខភាព និងសេវាកម្ម ព្រមទាំងទំនិញចាំបាច់ដទៃទៀត។ នេះជាការពិតដែលយើងត្រូវការប្រភេទនៃការគិតប្រកបដោយនវានុវត្តន៍។

**ខ្ញុំសូមគូសបញ្ជាក់ផងដែរ ពីភាពចាំបាច់ក្នុងការគោរពសិទ្ធិពលរដ្ឋ និងនយោបាយ នៅក្នុងអំឡុងពេលមានវិបត្តិនេះ។**

រដ្ឋាភិបាលជាច្រើន កំពុងប្រឈមនឹងការសម្រេចចិត្តដ៏លំបាក។ វិធានការបន្ទាន់ អាចនឹងត្រូវការដើម្បីឆ្លើយតបទៅនឹងភាពអាសន្នខាងសុខភាពសាធារណៈ។ ប៉ុន្តែ ស្ថានភាពបន្ទាន់នេះ មិនមែនគ្មានការត្រួតពិនិត្យ មិនគិតគូរពីកាតព្វកិច្ចសិទ្ធិមនុស្សនោះឡើយ។

វិធានការបន្ទាន់ គួរតែចាំបាច់ និងសមាមាត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនោះ។ ប្រជាជន គួរត្រូវបានជូនដំណឹងឲ្យបានពេញលេញអំពីវិធានការបន្ទាន់ និងបានប្រាប់ពីរយៈពេលប៉ុន្មានដែលវិធានការទាំងនោះនឹងមានប្រសិទ្ធភាពអនុវត្ត។ ការអនុវត្តវិធានការបន្ទាន់ ចាំបាច់ត្រូវអនុវត្តដោយស្មើភាពគ្នា និងប្រកបដោយមនុស្សធម៌។ ការពិន័យណាមួយ គួរតែមានលក្ខណៈសមាមាត្រទៅនឹងបទល្មើសដែលបានប្រព្រឹត្ត និងដែលមានចែងក្នុងច្បាប់។

ខ្ញុំមានកង្វល់ជាខ្លាំងចំពោះបណ្តាប្រទេសមួយចំនួន ដែលបានអនុម័តអំណាចបន្ទាន់ ដែលគ្មានដែនកំណត់ និងមិនដាក់ឲ្យស្ថិតក្នុងការពិនិត្យឡើងវិញ។ ក្នុងករណីមួយចំនួន ជំងឺរាតត្បាត កំពុងត្រូវបានគេប្រើធ្វើជាហេតុផលសម្រាប់ការផ្លាស់ប្តូរបែបផ្តាច់ការលើច្បាប់ធម្មតា ដែលនឹងនៅតែមានអានុភាពអនុវត្តដ៏យូរ បន្ទាប់ពីភាពអាសន្នបានបញ្ចប់។

ខ្ញុំក៏មានកង្វល់ផងដែរ អំពីវិធានមួយចំនួនដែលត្រូវបានអនុវត្ត ដើម្បីដាក់ការរិតត្បិតទៅលើសេរីភាពសារព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិ។ វិធានការមិនច្បាស់លាស់ដែលត្រូវបានបង្កើតឡើងប្រយុទ្ធប្រឆាំងនឹងការចោទប្រកាន់ពី "ការផ្សាយព័ត៌មានមិនពិត" អាចត្រូវបានអនុវត្តចំពោះការរិះគន់ណាមួយ ហើយនៅក្នុងប្រទេសខ្លះ យើងបានឃើញរបាយការណ៍ពីអ្នកសារព័ត៌មានមួយចំនួន ត្រូវបានគេដាក់ទោសទណ្ឌ ព្រោះតែរាយការណ៍អំពីកង្វះម៉ាស់មុខ បុគ្គលិកសុខាភិបាល ត្រូវបានស្តីបន្ទោស ដោយសារតែ

ការនិយាយថាពួកគេខ្វះសម្ភារៈការពារ ហើយប្រជាជនសាមញ្ញ ត្រូវបានចាប់ខ្លួន ដោយសារតែការបង្ហោះលើបណ្តាញសង្គមអំពីជំងឺរាតត្បាតនេះ។ មតិរិះគន់ មិនមែនជាបទល្មើសនោះទេ។

ខ្ញុំសូមជម្រុញឲ្យរដ្ឋាភិបាលទាំងអស់ បង្កើនលទ្ធភាពទទួលបានព័ត៌មាន និងស្ថិតិឲ្យបានត្រឹមត្រូវ។ តម្លាភាព គឺមានសារៈសំខាន់បំផុត ហើយអាចជួយសង្គ្រោះជីវិតមនុស្សនៅក្នុងវិបត្តិសុខភាព។ ខ្ញុំក៏សូមជម្រុញឲ្យបញ្ឈប់ការបិទសេវាកម្មអ៊ីនធឺណិត និងទូរគមនាគមន៍ ដែលត្រូវបានបិទ និងការបដិសេធសេវាកម្មនេះ។

នៅពេលដែលសមាជិកនៃកងកម្លាំងយោធាបំពេញមុខងារអនុវត្តច្បាប់ ពួកគេ គួរតែទទួលខុសត្រូវចំពោះអាជ្ញាធរស៊ីវិល ហើយពួកគេ នៅតែស្ថិតនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិជាដដែល។

អង្គការសុខភាពពិភពលោក ណែនាំយ៉ាងមុតមាំថា វិធានការសុខភាព និងសង្គម ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩(COVID-19) ត្រូវបានអនុវត្តដោយមានការចូលរួមយ៉ាងពេញលេញពីសាធារណជន ពីព្រោះការគោរពសិទ្ធិមនុស្ស រួមទាំងសិទ្ធិក្នុងការនិយាយស្តី និងការចូលរួមក្នុងការសម្រេចចិត្តប្រកបដោយអត្ថន័យ គឺជាមធ្យោបាយដ៏សំខាន់នៃគោលនយោបាយសុខភាពដ៏ជោគជ័យ។ មធ្យោបាយដ៏មានប្រសិទ្ធភាពតែមួយគត់ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត គឺការជឿទុកចិត្តពីសាធារណជន។

## អ្វីដែលត្រូវធ្វើ?

ខ្ញុំឃើញមានសកម្មភាពពីរយ៉ាង៖ ការឆ្លើយតបជាបន្ទាន់ទៅនឹងការរាលដាល និងការរៀបចំសម្រាប់ពេលជាសះស្បើយឡើងវិញ។

ទាក់ទងនឹងការឆ្លើយតប ខ្ញុំចង់ចែករំលែកជាមួយអ្នកនូវចំណុចសកម្មភាពមួយចំនួន ដែលពាក់ព័ន្ធភ្លាមៗ ហើយនឹងជួយក្នុងការបង្កើតគោលនយោបាយមនុស្សធម៌ និងមានប្រសិទ្ធភាព។

១. រាល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ គួរតែសំដៅកាត់បន្ថយផលប៉ះពាល់នៃជំងឺរាតត្បាតទៅលើស្ត្រី និងក្រុមងាយរងគ្រោះ។

**ស្ត្រី** ទំនងជាមានចំនួនច្រើនជាងបុរស ដែលធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ និងដែលមានប្រាក់ឈ្នួលទាប ដោយគ្មានរបបឈប់សម្រាកឈឺមានប្រាក់ឈ្នួល ការធានារ៉ាប់រងសុខភាព ឬការការពារសង្គម។ ស្ត្រីវ័យចំណាស់ ទំនងជាមានចំនួនច្រើនជាងបុរស ដែលត្រូវទទួលរ៉ាប់រងចិញ្ចឹមជីវិតដោយមិនមានប្រាក់សោធននិវត្តន៍។ វិធានការបង្ខាំងមនុស្ស កំពុងបង្កើតបន្ទុកបន្ថែមសម្រាប់ស្ត្រីជាច្រើន រួមមានបន្ទុកថែទាំអ្នកមានជំងឺ មនុស្សចាស់ជរា ហើយកុមារខកខានការសិក្សារៀនសូត្រ។ ស្ត្រី និងកុមារី កំពុងប្រឈមនឹង

ហានិភ័យកើនឡើងពីអំពើហឹង្សាក្នុងគ្រួសារផងដែរ ដូចដែលបានបង្ហាញក្នុងស្ថិតិថ្មីៗនេះពីប្រទេសបារាំង និងអេស្ប៉ាញ។ សម្រាប់គោលបំណងនៃការសិក្សាពីចម្ងាយ ក្មេងស្រីនៅទូទាំងពិភពលោកមានលទ្ធភាពប្រើប្រាស់អ៊ិនធឺណែត និងទូរស័ព្ទចល័ត តិចជាងក្មេងប្រុស។ ផលប៉ះពាល់ទាំងនេះ ប្រហែលជាមិនអាចមើលឃើញភ្លាមៗទេ ប៉ុន្តែវាអាចកំណត់មូលហេតុនៃសមភាពរបស់ស្ត្រី។

ក្រុមដែលមានហានិភ័យខ្ពស់ និងក្រុមងាយរងគ្រោះជាច្រើន ត្រូវការការយកចិត្តទុកដាក់ខ្លាំងថែមទៀត និងវិធានការកាត់បន្ថយហានិភ័យ នៅពេលនេះ។ ក្រុមទាំងនេះ រាប់បញ្ចូលទាំង **អ្នកទាំងឡាយដែលស្ថិតក្នុងកន្លែងឃុំឃាំង និងនៅក្នុងស្ថាប័នដទៃផ្សេងទៀត** - រួមទាំងស្ថាប័នផ្នែកវិកលចរិក និងមណ្ឌលកុមារកំព្រា- **ជនមានពិការភាព ជនជាតិដើមភាគតិច និងជនជាតិភាគតិច ជនចំណាកស្រុក ជនភៀសខ្លួន និងប្រជាជនផ្លាស់ទីលំនៅ ប្រជាជននៅក្នុងតំបន់ជម្លោះ ហើយជាពិសេស មនុស្សចាស់** ជាពិសេសអ្នកដែលរស់នៅតែម្នាក់ឯង ឬនៅតាមស្ថាប័ននានា។

សេចក្តីណែនាំជាក់លាក់ចំពោះក្រុមទាំងនេះ ភាគច្រើនត្រូវបានចេញ ឬបាននិងកំពុងរៀបចំ។

ជាពិសេស ខ្ញុំសូមទាញចំណាប់អារម្មណ៍អ្នកអំពីការណែនាំរបស់យើងទាក់ទងនឹង**មនុស្សស្ថិតក្នុងមន្ទីរឃុំឃាំង** ដែលចំនួនរបស់ពួកគេ គួរតែត្រូវបានកាត់បន្ថយយ៉ាងប្រុងប្រយ័ត្ន ដើម្បីចៀសវាងការរីករាលដាលនៃមេរោគនៅក្នុងកន្លែងបិទជិត និងកន្លែងចង្អៀតណែន។ ថ្មីៗនេះ ប្រទេសអ៊ីរ៉ង់ បានចាត់វិធានការដោះលែង (យ៉ាងហោចណាស់ជាបណ្តោះអាសន្ន) ៤០ ភាគរយនៃចំនួនជនជាប់ឃុំក្នុងពន្ធនាគាររបស់ខ្លួន។ ប្រទេសឥណ្ឌូនេស៊ី ក៏នឹងដោះលែងជនជាប់ចោទបទលហុមួយចំនួនផងដែរ។ ហើយថា ប្រទេសមួយចំនួនផ្សេងទៀត ក៏ធ្វើអញ្ចឹងដែរ។ ខ្ញុំសូមជម្រុញឲ្យរដ្ឋទាំងអស់ ដោះលែងជនជាប់ឃុំដែលគ្មានមូលដ្ឋានច្បាប់ រួមទាំងអ្នកទាំងឡាយដែលត្រូវគេឃុំខ្លួន ដោយរំលោភលើកាតព្វកិច្ចសិទ្ធិមនុស្ស។ ខ្ញុំក៏មានកង្វល់ផងដែរថា ប្រទេសមួយចំនួនកំពុងគិតដល់ការកាត់ទោសពន្ធនាគារពីបទរំលោភលើបទបញ្ជាទាក់ទងនឹងការដាក់គម្លាតនៅឃ្លាតឆ្ងាយពីគ្នាខាងរូបកាយ៖ ដែលនេះ ទំនងជាធ្វើឲ្យកាន់តែមានភាពធ្ងន់ធ្ងរបន្ថែមពីលើជំងឺរាតត្បាត។

**ជនមានពិការភាព** ជារឿយៗ ត្រូវពឹងផ្អែកលើអ្នកដទៃជួយ ដើម្បីបំពេញភារកិច្ចប្រចាំថ្ងៃ ហើយបទបញ្ជាបង្ខាំង គួរតែធានាឲ្យពួកគេអាចទទួលបានការគាំទ្របែបនេះ។

**ជនចំណាកស្រុក**ជាច្រើន មានហានិភ័យខ្ពស់នៃការឆ្លង ដោយសារតែស្ថានភាពរស់នៅរបស់ពួកគេ និងការទទួលបានកិច្ចគាំពារសុខភាពមានកម្រិត។ ខ្ញុំសូមកោតសរសើរចំពោះប្រទេសព័ទុយហ្កាល់ ដែលបានចាត់វិធានការកាលពីសប្តាហ៍មុន ដើម្បីផ្តល់ជាបណ្តោះអាសន្នដល់ជនចំណាកស្រុកទាំងអស់នៅក្នុង

ប្រទេសរបស់ខ្លួន ឲ្យមានសិទ្ធិពលរដ្ឋពេញលេញ ដើម្បីឲ្យពួកគេទទួលបានប្រព័ន្ធគាំពារសុខភាពទាំងអស់។

២. វិធានការទូលំទូលាយ ត្រូវបានចាត់ឡើងនៅគ្រប់ប្រទេស ដើម្បីស្រូបយកវិបត្តិសេដ្ឋកិច្ច និងសង្គមនៃការរាតត្បាតនេះ និងដើម្បីកាត់បន្ថយការពង្រីកវិសមភាព។

នៅគ្រប់ទិសទី ការរាតត្បាត ទំនងជាធ្វើឲ្យមាន**វិសមាមាត្រទៅលើជនក្រីក្រ។** ឧទាហរណ៍ ព័ត៌មានពីអាជ្ញាធរតំបន់កាតាឡាន នៅប្រទេសអេស្ប៉ាញ បង្ហាញថា អ្នករស់នៅជិតខាងដែលក្រីក្រ អាចនឹងឆ្លងជំងឺនេះ ៦ ទៅ ៧ ដង ច្រើនជាងមនុស្សនៅតំបន់នេះ ដែលជាអ្នកមាន។

មានតម្រូវការខ្ពស់សម្រាប់វិធានការរបស់រដ្ឋាភិបាល ដើម្បីធានាសន្តិសុខប្រាក់ចំណូល ការការពារមុខរបរចិញ្ចឹមជីវិត និងលទ្ធភាពទទួលបាននូវទំនិញ និងសេវាកម្មចាំបាច់ សម្រាប់សមាជិកក្រីក្របំផុតនៃសង្គម។ នេះជាចាំបាច់ណាស់ ក្នុងការការពារមនុស្សពីការក្លាយទៅជាជនអនាថា ដែលជាលទ្ធផលនៃការបាត់បង់ការងារ។ ជំនួយជាសាច់ប្រាក់ គួរតែត្រូវបានពិចារណា រួមជាមួយនឹងវិធានការនានា ដើម្បីធានាថាគ្រួសារទាំងឡាយ អាចពន្យារពេលការជួល ឬការទូទាត់ប្រាក់កម្ចី និងបញ្ឈប់ការបណ្តេញចេញ។ សម្រាប់ជនអនាថា និងអ្នកផ្សេងទៀតដែលគ្មានផ្ទះសម្បែងសមរម្យ វិធានការនានា អាចរាប់បញ្ចូលទាំងការជួលរយៈពេលខ្លី និងកន្លែងស្នាក់នៅបន្ទាន់។

ការិយាល័យខ្ញុំ បច្ចុប្បន្នកំពុងចងក្រងការអនុវត្តល្អខាងវិស័យសេដ្ឋកិច្ច និងសង្គម ដែលត្រូវបានអនុម័តដោយប្រទេសនានា នៅក្នុងតំបន់ដែលភាគច្រើនជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយយើងនឹងនាំយកការអនុវត្តល្អទាំងនេះ ឲ្យអ្នកចាប់អារម្មណ៍។ យើងនឹងធ្វើការផងដែរ ដើម្បីបញ្ចូលសិទ្ធិមនុស្សទៅក្នុងការងារទាំងអស់នៃកម្មវិធីសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ។

**៣. ការការពារបុគ្គលិកសុខាភិបាល** និងប្រាក់ឈ្នួលគ្រប់គ្រាន់ គួរតែជាក្តីកង្វល់ដ៏ធំមួយ។ ជាការកត់សម្គាល់ ៧០ ភាគរយនៃបុគ្គលិកសុខភាពពិភពលោក គឺជាស្ត្រី ដែលពួកគេភាគច្រើន អាចប្រឈមនឹងបន្ទុកបន្ថែម ដែលខ្ញុំបានកត់សម្គាល់។

៤. នៅពេលដែលការគំរាមកំហែងនៅចំពោះមុខ យើងទាំងអស់គ្នា **មិនមានកន្លែងសម្រាប់ជាតិនិយម ឬការស្តីបន្ទោសគ្នាឡើយ** - រួមទាំងជនចំណាកស្រុក និងសហគមន៍ជនជាតិភាគតិច។ មានការវាយប្រហារលើរូបកាយ និងតាមរយៈពាក្យសំដី កំពុងតែកើនឡើង និងដែលមិនអាចទទួលយកបាន លើប្រជាជនដើមកំណើតអាស៊ីបូព៌ា និងសមាជិកជនជាតិភាគតិចដទៃទៀត ហើយគួរតែមានចំណាត់វិធានការ

ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ។ ជាការពិត ប្រជាជនលោកខាងលិច ពេលខ្លះត្រូវបានគេកំណត់គោលដៅសម្រាប់ការរំលោភបំពាន រួមទាំងនៅក្នុងបេសកកម្មរបស់យើងផងដែរ។

៥. នៅគ្រប់ដំណាក់កាលនៃការរីករាលដាលនៃជំងឺនេះ រួមទាំងការជាសះស្បើយឡើងវិញ គួរតែមានកិច្ចខិតខំប្រឹងប្រែងឲ្យមានការចូលរួមពី**ស្ថាប័នសិទ្ធិមនុស្សជាតិ សកម្មជនសង្គមស៊ីវិល** និងអ្នកការពារសិទ្ធិមនុស្សផងដែរ។ អ្នកដែលមានការចូលរួមយូរអង្វែងនៅក្នុងសិទ្ធិសេដ្ឋកិច្ច និងសង្គម សហគមន៍ទីក្រុង និងក្រុមងាយរងគ្រោះជាក់លាក់ ដូចជាជនជាតិដើមភាគតិច បានទទួលមេរៀនដ៏មានតម្លៃជាច្រើន ដែលអាចផ្តល់ជាប្រយោជន៍ដល់អ្នកធ្វើគោលនយោបាយទាំងអស់ នាពេលបច្ចុប្បន្ននេះ។

៦. រាល់ឧបសគ្គចំពោះកិច្ចខិតខំប្រឹងប្រែងផ្នែកវេជ្ជសាស្ត្រនៅក្នុងប្រទេសមួយ បង្កើនហានិភ័យសម្រាប់យើងទាំងអស់គ្នា។ **ទណ្ឌកម្ម**តាមវិស័យដែលជះឥទ្ធិពលអវិជ្ជមានដល់កិច្ចគាំពារសុខភាព និងសិទ្ធិមនុស្សរបស់ជនងាយរងគ្រោះ គួរតែត្រូវបានដកចេញ ឬកែសម្រួលជាបន្ទាន់ ដោយមានការលើកលែងផ្នែកមនុស្សធម៌ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាលទ្ធភាពទទួលបានការផ្គត់ផ្គង់ចាំបាច់។

៧. ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងដែលបាននិងកំពុងធ្វើ ដើម្បីធានាថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស អាចជួយទាន់ពេលវេលាចំពោះកង្វល់អំពីសិទ្ធិមនុស្សទាក់ទងនឹងជំងឺកូវីដ១៩(COVID-19)។ ក្រោមការដឹកនាំរបស់លោកជំទាវ លោកជំទាវប្រធាន ក្រុមប្រឹក្សាសិទ្ធិមនុស្ស កំពុងបន្តការងាររបស់ខ្លួន។ បន្ថែមលើការរាយការណ៍ក្រៅផ្លូវការនេះ ការប្រជុំតាមប្រព័ន្ធអេឡិចត្រូនិចជាបន្តបន្ទាប់ជាមួយអ្នកពាក់ព័ន្ធនានា កំពុងត្រូវបានគ្រោងទុក ហើយខ្ញុំយល់ថា មានការពិភាក្សាទាក់ទងនឹងសម័យប្រជុំពិសេស ស្តីពីជំងឺកូវីដ១៩(COVID-19)។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការវិភាគយ៉ាងឆាប់រហ័ស និងដែលពាក់ព័ន្ធរបស់អ្នកកាន់អាណត្តិនីតិវិធីពិសេសជាច្រើន និងប្រធានស្ថាប័នសន្ធិសញ្ញាផ្សេងៗ។

នៅទូទាំងដំណាក់កាលឆ្លើយតប និងដំណាក់កាលជាសះស្បើយពីជំងឺរាតត្បាត យើងទាំងអស់គ្នាត្រូវតែបង្កើន និងបង្ហាញ**សាមគ្គីភាពជាសាកល**។ ក្នុងបរិបទនេះ ខ្ញុំសូមរំលឹកដល់រដ្ឋទាំងអស់ អំពីកាតព្វកិច្ចនៃកិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ ក្រោមមាត្រា២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

**មុននឹងបញ្ចប់ ខ្ញុំសូមធ្វើការកត់សម្គាល់មួយចំនួនអំពីការងើបចេញពីវិបត្តិនេះ។**

ដូចដែលអគ្គលេខាធិការបានគូសបញ្ជាក់ យើងត្រូវតែកសាងឡើងវិញឲ្យកាន់តែប្រសើរឡើង។ គ្មានប្រទេសណាមួយ ត្រូវបានគេរៀបចំសម្រាប់ភាពតក់ស្លុតនេះទេ ដែលនៅក្នុងរដ្ឋនីមួយៗកាន់តែធ្ងន់ធ្ងរ

ទៅៗ ដោយសារវិសមភាព ជាពិសេស ក្នុងការទទួលបានកិច្ចគាំពារសុខភាព ការការពារសង្គម និងសេវាកម្មសាធារណៈ។

ការរាតត្បាត បានបញ្ជាក់ពីភាពចាំបាច់ ក្នុងការបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បី**ធានាថា ប្រជាជនទាំងអស់ រួមទាំងជនងាយរងគ្រោះបំផុត ទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍ**។ យើងចាំបាច់ត្រូវខិតខំប្រឹងប្រែងទ្វេរដង ដើម្បីកសាងសេដ្ឋកិច្ចប្រកបដោយចីរភាព និងមានបរិយាបន្នបន្ថែមទៀត និងបង្កើតឲ្យមានសង្គមដែលមានភាពធន់ នៅចំពោះមុខវិបត្តិនេះ។ របៀបវារៈឆ្នាំ២០៣០ ត្រូវបានរៀបចំផែនការពេញលេញ និងអនុម័តជាសាកលៈ របៀបវារៈនេះ នៅតែជាឧបករណ៍ដ៏រឹងមាំបំផុតរបស់យើង។

គួរបញ្ជាក់ផងដែរថា **ការការពារបរិស្ថាន** ជានានូវជីវៈចម្រុះ គឺជាមធ្យោបាយដ៏ល្អបំផុត ក្នុងការការពារសុខភាព និងសុខុមាលភាពរបស់មនុស្ស រួមទាំងពីជំងឺរាតត្បាត។ ការរិចរិលបរិស្ថាន និងការបាត់បង់ជីវចម្រុះ បង្កើតលក្ខខណ្ឌសម្រាប់ប្រភេទជំងឺដែលឆ្លងពីសត្វទៅមនុស្ស ដែលបណ្តាលឲ្យមានការរីករាលដាលយ៉ាងខ្លាំងម្តងហើយម្តងទៀត។ មិនត្រឹមតែជំងឺកូវីដ១៩(COVID-19) ទេ - អ្នកនឹងចងចាំជំងឺ SARS, MERS និង Ebola ក៏ជាផលកើតចេញពីសត្វ ដូច្នេះ យើងត្រូវធានាឲ្យមានការគោរពបរិស្ថាន។

យើងមិនត្រឹមតែមិនអាចវិលត្រឡប់ទៅកាន់កន្លែងដែលយើងទើបបានស្ថិតនៅកាលពី ពីរ បីខែមុនប៉ុណ្ណោះទេ មុនពេលកើតមានជំងឺកូវីដ១៩(COVID-19) ។

នេះគឺជាការសាកល្បងដ៏ធំសម្បើមនៃភាពជាអ្នកដឹកនាំ។ វាទាមទារឲ្យមានសកម្មភាពដាច់ខាត មានការសម្របសម្រួល និងប្រកបដោយនវានុវត្តន៍ពីអ្នកទាំងអស់គ្នា និងសម្រាប់គ្រប់គ្នា។ បច្ចុប្បន្ននេះ យើងឃ្លាតឆ្ងាយពីគ្នាតែរូបកាយ ប៉ុន្តែយើងត្រូវតែឈរជាមួយគ្នា។

អ្នកទាំងអស់គ្នាបានទទួលលិខិត ដែលជូនដំណឹងទៅលោកជំទាវអំពីការងារដែលកំពុងដំណើរការដោយការិយាល័យរបស់ខ្ញុំ ក្នុងបរិបទនៃជំងឺកូវីដ១៩(COVID-19) ហើយខ្ញុំនឹងផ្តល់ព័ត៌មានថ្មីៗជាទៀងទាត់ដល់លោកជំទាវ នៅពេលមានស្ថានភាពវិវឌ្ឍន៍។ ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណជាសាធារណៈដល់បុគ្គលិកទាំងអស់ ដែលបានប្តេជ្ញាចិត្តបន្តធ្វើការនៅក្នុងគ្រាលំបាកនេះ។

សូមអរគុណលោកជំទាវប្រធាន